# ក្រដាសព័ត៌មាន
# ការតវ៉ានៅក្រោមច្បាប់ការរើសអើងជាតិសាសន៍

## តើអ្វីទៅជាច្បាប់ការរើសអើងជាតិសាសន៍?

*ច្បាប់ការរើសអើងជាតិសាសន៍ឆ្នាំ 1975* (Cth) (the RDA) បង្កើតឡើងប្រឆាំងនឹងច្បាប់ដែលប្រព្រឹត្តិលើអ្នកមិនត្រឹមត្រូវ ដោយសារតែជាតិសាសន៍ ពណ៌សម្បុរ ដើមកំណើត ប្រភពជាតិ ឬជនជាតិ ឬស្ថានភាពជនអន្តោប្រវេសន៍។

ច្បាប់នេះក៏បង្កើតឡើងដើម្បីធ្វើឱ្យសម្អប់ខាងជាតិសាសន៍ថាជាការប្រឆាំងនឹងច្បាប់។

## តើច្បាប់នេះអាចត្រូវបានប្រើប្រាស់នៅពេលណា?

អ្នកអាចប្រើប្រាស់ RDA ដើម្បីទទួលបានការប្រព្រឹត្តិឱ្យបានត្រឹមត្រូវនៅក្នុងវិស័យជាច្រើននៃជីវិតសាធារណៈ៖

- **ការងារ** – ការទទួលបានការងារ វាក្យសព្ទ និងលក្ខខណ្ឌនៃការងារ ការដំឡើងឋានៈ ការដែលត្រូវបានគេបណ្តេញចេញពីការងារ។
- **ការអប់រំ** – ការចុះឈ្មោះចូលរៀន ឬការសិក្សានៅសាលារៀនឯកជន ឬសាធារណៈ នៅមហាវិទ្យាល័យ ឬសកលវិទ្យាល័យ។
- **កន្លែងស្នាក់នៅ** – ការជួល ឬទិញផ្ទះ ឬផ្ទះល្វែង។
- **ការទទួលបាន ឬការប្រើប្រាស់សេវាកម្ម** – ដូចជាសេវាកម្មធនាគារ ឬការធានារ៉ាប់រង សេវាកម្មនានាដែលបានផ្តល់ដោយក្រសួងរបស់រដ្ឋាភិបាល ការដឹកជញ្ជូន ឬសេវាកម្មទូរគមនាគមន៍ សេវាកម្មជំនាញ ដូចជាសេវាកម្មនានាដែលបានផ្តល់ឱ្យដោយមេធាវី វេជ្ជបណ្ឌិត ឬអ្នកធ្វើជំនួញ សេវាកម្មនានាដែលបានផ្តល់ឱ្យដោយភោជនីយដ្ឋាន ហាងលក់ទំនិញ ឬកន្លែងកម្សាន្ត។
- **ការចូលប្រើប្រាស់កន្លែងសាធារណៈ** – ដូចជាសួន ការិយាល័យរដ្ឋាភិបាល ភោជនីយដ្ឋាន សណ្ឋាគារ ឬមជ្ឈមណ្ឌលលក់ទំនិញ។

## តើអ្វីទៅជាការរើសអើងជាតិសាសន៍?

ការរើសអើងជាតិសាសន៍កើតឡើងនៅពេលមនុស្សម្នាក់ត្រូវបានប្រព្រឹត្តិលើដោយមានការពេញចិត្តតិចជាងមនុស្សម្នាក់ទៀតនៅក្នុងស្ថានភាពស្រដៀងគ្នា ដោយសារតែជាតិសាសន៍ ពណ៌សម្បុរ ដើមកំណើត ប្រភពជាតិ ឬជនជាតិ ឬស្ថានភាពជនអន្តោប្រវេសន៍របស់ពួកគេ។ ឧទាហរណ៍ វាជា ‘ការរើសអើងដោយផ្ទាល់’ ប្រសិនបើភ្នាក់ងារអចលនទ្រព្យបដិសេធជួលផ្ទះទៅឱ្យមនុស្សម្នាក់ ដោយសារពួកគេស្ថិតនៅក្នុងប្រវត្តិជាតិសាសន៍ ឬពណ៌ស្បែកជាក់លាក់។

ការរើសអើងជាតិសាសន៍ក៏កើតឡើងផងដែរនៅពេលមានបទបញ្ញត្តិ ឬគោលនយោបាយមួយដែលមានដូចគ្នាសម្រាប់មនុស្សគ្រប់រូប ប៉ុន្តែមានផលប៉ះពាល់មិនត្រឹមត្រូវទៅលើមនុស្សដែលមានជាតិសាសន៍ ពណ៌សម្បុរ ដើមកំណើត ប្រភពជាតិ ឬជនជាតិ ឬស្ថានភាពជនអន្តោប្រវេសន៍ជាក់លាក់។ នេះហៅថា ‘ការរើសអើងដោយប្រយោល’។ ឧទាហរណ៍ វាអាចជាការរើសអើងដោយប្រយោល ប្រសិនបើក្រុមហ៊ុនមួយនិយាយប្រាប់និយោជិកថាមិនត្រូវពាក់មួក ឬវត្ថុគ្របក្បាល

ផ្សេងទៀតនៅកន្លែងធ្វើការទេ ពីព្រោះការនេះទំនងជាមានផលប៉ះពាល់មិនត្រឹមត្រូវទៅលើមនុស្ស ដែលចេញមកពីប្រវត្តិជាតិសាសន៍/ជនជាតិមួយចំនួន។

## តើអ្វីទៅជាសម្អប់ខាងជាតិសាសន៍?

វាជាការប្រឆាំងនឹងច្បាប់ដោយធ្វើអ្វីមួយជាសាធារណៈដោយផ្អែកលើជាតិសាសន៍ ពណ៌សម្បុរ ប្រភពជាតិ ឬជនជាតិរបស់មនុស្សម្នាក់ ឬក្រុមមនុស្សដែលទំនងជា**រំលោភបំពាន ប្រមាថ ធ្វើឱ្យអាម៉ាស់មុខ ឬគំរាមកំហែង**។

ឧទាហរណ៍មួយចំនួននៃសម្អប់ជាតិសាសន៍ អាចរួមមានលក្ខណៈជាតិសាសន៍៖

- សម្ភារមានលក្ខណៈរំលោភបំពាននៅលើអ៊ីនធឺណិត រួមមានវេទិកាអេឡិចត្រូនិក ប្លក់ គេហទំព័របណ្តាញសង្គម និងគេហទំព័រចែករំលែកវីដេអូ។

- មតិ ឬរូបភាពមានលក្ខណៈរំលោភបំពាននៅក្នុងបោះពុម្ពផ្សាយដូចជា សារព័ត៌មាន ទស្សនាវដ្តី ខិត្តប័ណ្ណ ឬផ្ទាំងព័ត៌មាន

- សុន្ទរកថាមានលក្ខណៈរំលោភបំពាននៅឯការប្រមូលផ្តុំសាធារណៈ

- មតិមានលក្ខណៈរំលោភបំពាននៅក្នុងកន្លែងសាធារណៈដូចជា ហាងលក់ទំនិញ កន្លែងធ្វើការ សួន នៅលើមធ្យោបាយដឹកជញ្ជូនសាធារណៈ ឬនៅសាលារៀន

- មតិមានលក្ខណៈរំលោភបំពានធ្វើឡើងដោយកីឡាករ ទស្សនិកជន គ្រូបង្វឹក ឬមន្ត្រីនានានៅឯព្រឹត្តិការណ៍កីឡា។

## នៅពេលណាដែលឥរិយាបថមានលក្ខណៈរំលោភបំពាន់ផ្អែកលើជាតិសាសន៍ជាការប្រឆាំងនឹងច្បាប់?

RDA មានគោលបំណងធ្វើឱ្យមានតុល្យភាពរវាងសិទ្ធិធ្វើទំនាក់ទំនងដោយសេរី (‘សេរីភាពនៃការបញ្ចេញមតិ’) និងសិទ្ធិរស់នៅដោយសេរីពីសម្អប់ជាតិសាសន៍។ RDA ចាត់ទុករឿងមួយចំនួនដូចតទៅនេះថាមិនប្រឆាំងនឹងច្បាប់ប្រសិនបើរឿងនោះ **“ត្រូវបានធ្វើឡើងដោយសមហេតុផល និងដោយស្មោះត្រង់”** នៅក្នុង៖

- **ការងារសិល្បៈ ឬការសម្តែងសិល្បៈ** – ឧទាហរណ៍ ល្ខោនបង្ហាញចរិករំលោភបំពាន ខាងជាតិសាសន៍ ដែលត្រូវបានបង្ហាញដោយតួអង្គម្នាក់។

- **សេចក្តីថ្លែងការ ការបោះពុម្ពផ្សាយ ការជជែក និងការពិភាក្សាដែលបានធ្វើឡើង សម្រាប់ការសិក្សាដោយស្មោះត្រង់ ឬគោលបំណងផ្នែកវិទ្យាសាស្ត្រ** – ឧទាហរណ៍ ការជជែក និងការពិភាក្សាលើគោលនយោបាយ សាធារណៈដូចជារឿងអន្តោប្រវេសន៍ ពហុវប្បធម៌ ឬវិធានការពិសេសសម្រាប់ក្រុម ជាក់លាក់មួយចំនួន។

- **ធ្វើរបាយការណ៍ដោយយុត្តិធម៌ និងត្រឹមត្រូវស្តីពីបញ្ហានៃផលប្រយោជន៍សាធារណៈ** – ឧទាហរណ៍ របាយការណ៍ដោយយុត្តិធម៌នៅក្នុងសារព័ត៌មានអំពីការប្រព្រឹត្តិដោយរំលោភបំពានខាងជាតិសាសន៍។

- **ធ្វើការបង្ហាញមតិដោយត្រឹមត្រូវ** ប្រសិនបើមតិគឺជាការបញ្ចេញនូវជំនឿដោយស្មោះត្រង់របស់មនុស្សម្នាក់។

## តើខ្ញុំអាចធ្វើអ្វីបាន ប្រសិនបើខ្ញុំជួបប្រទះការរើសអើង ឬសម្អប់ខាងជាតិសាសន៍?

អ្នកប្រហែលជាចង់លើកឡើងពីរឿងនេះដោយផ្ទាល់ជាមួយមនុស្សម្នាក់ ឬមនុស្សនានាដែល ពាក់ព័ន្ធ។

ប្រសិនបើធ្វើដូចនេះមិនដោះស្រាយបានទេ ឬអ្នកមិនមានអារម្មណ៍សុខស្រួលក្នុងការធ្វើការនេះទេ អ្នកអាចតវ៉ាទៅគណៈកម្មការសិទ្ធិមនុស្សអូស្ត្រាលី។ អ្នកក៏អាចរកអ្នកណាម្នាក់ដូចជាមេធាវី អ្នកផ្តល់ឱវាទ ឬសហជីពដើម្បីតវ៉ាជំនួសឱ្យអ្នកបាន។

មិនត្រូវការចំណាយទៅលើអ្វីទេក្នុងតវ៉ាទៅគណៈកម្មការ។

ការតវ៉ារបស់អ្នកត្រូវធ្វើជាលាយលក្ខណ៍អក្សរ។ គណៈកម្មការមានទម្រង់បែបបទតវ៉ាសម្រាប់អ្នកអាចបំពេញវាបាន ហើយផ្ញើវាតាមប្រៃសណីយ៍ ឬផ្ញើតាមទូរសារទៅយើង ឬអ្នកអាចដាក់ពាក្យតវ៉ាតាមអ៊ីនធឺណិតនៅឯគេហទំព័ររបស់យើង។
ប្រសិនបើអ្នកមិនអាចដាក់ការតវ៉ារបស់អ្នកជាលាយលក្ខណ៍អក្សរបានទេ យើងអាចជួយអ្នកបាន។

សម្រាប់ឱ្យការតវ៉ារបស់អ្នកមានសុពលភាព ការតវ៉ាត្រូវតែមានអំណះអំណាងសមហេតុផលចំពោះព្រឹត្តិការណ៍នានាដែលអ្នកចង់តវ៉ាថាជាការរើសអើងខុសច្បាប់ ហើយអ្នកត្រូវតែផ្តល់ព័ត៌មានលម្អិតឱ្យបានគ្រប់គ្រាន់អំពីការចោទប្រកាន់របស់អ្នក រួមមានអ្វីដែលបានកើតឡើងនៅពេលណា និងវាកើតឡើងនៅពេលណា ហើយអ្នកណាខ្លះជាប់ពាក់ព័ន្ធ។

ការតវ៉ាអាចត្រូវបានធ្វើឡើងជាភាសាអ្វីក៏បាន។ ប្រសិនបើអ្នកត្រូវការអ្នកបកប្រែសរសេរ ឬអ្នកបកប្រែផ្ទាល់មាត់ យើងអាចចាត់ចែងលើរឿងនេះបាន។

## តើខ្ញុំអាចទទួលបានព័ត៌មានបន្ថែមទៅកន្លែងណា?

ព័ត៌មានទំនាក់ទំនងលម្អិតរបស់គណៈកម្មការសិទ្ធិមនុស្សអូស្ត្រាលីមាន៖

**ទូរសព្ទ**
សេវាកម្មព័ត៌មានថ្នាក់ជាតិ៖ 1300 656 419 ឬ (02) 9284 9888
TTY: 1800 620 241 (ទូរសព្ទឥតគិតថ្លៃ)
ទូរសារ៖ (02) 9284 9611

**តាមប្រៃសណីយ៍Post**

GPO Box 5218
Sydney NSW 2001

**តាមអ៊ីនធឺណិតOnline**
អ៊ីមែល៖ infoservice@humanrights.gov.au
គេហទំព័រ៖ www.humanrights.gov.au

អ្នកអាចធ្វើការតវ៉ាតាមអ៊ីនធឺណិត
www.humanrights.gov.au/complaints_information/online_form/index.html.

ប្រសិនបើអ្នកថ្លង់ ឬមានការពិបាកក្នុងការស្តាប់ អ្នកអាចទាក់ទងយើងតាមរយៈ TTY តាមលេខ 1800 620 241។ ប្រសិនបើអ្នកត្រូវការអ្នកប្រែផ្ទាល់មាត់ Auslan យើងអាចចាត់ចែងរកអ្នកប្រែនេះបាន សម្រាប់អ្នក។

ប្រសិនបើអ្នកខ្វាក់ ឬមានការលំបាកផ្នែកចក្ខុ យើងអាចផ្តល់ព័ត៌មានជាទម្រង់បែបបទជំនួសវិញទៅតាមសំណើ។

## កន្លែងទំនាក់ទំនងផ្សេងទៀតសម្រាប់ការតវ៉ាអំពីសម្អប់ខាងជាតិសាសន៍

ប្រសិនបើអ្នកព្រួយបារម្ភអំពីរឿងរ៉ាវមេឌៀដែលមានលក្ខណៈរំលោភបំពាន ការផ្សព្វផ្សាយ ឬខ្លឹមសារនៅលើអ៊ីនធឺណិត អ្នកអាចតវ៉ាទៅអាជ្ញាធរទទួលបន្ទុកលើការធ្វើទំនាក់ទំនង និងមេឌៀ (ACMA) ក្រុមប្រឹក្សាស្តង់ដារនៃការផ្សាយពាណិជ្ជកម្មសម្រាប់ការផ្សាយពាណិជ្ជកម្ម ឬក្រុមប្រឹក្សាសារព័ត៌មានអូស្ត្រាលីសម្រាប់រឿងរ៉ាវចុះលើសារព័ត៌មាន។ អ្នកក៏អាចតវ៉ាទៅបណ្ណាធិការព័ត៌មាន ឬអ្នកគ្រប់គ្រងអង្គការមេឌៀបានដែរ។

ប្រសិនបើអ្នកព្រួយបារម្ភអំពីឥរិយាបថរំលោភបំពានដោយអ្នកជិតខាង អ្នកអាចទៅរកមជ្ឈមណ្ឌលយុត្តិធម៌សហគមន៍ ដើម្បីជួយដោះស្រាយបញ្ហា ឬទៅរកក្រសួងទទួលបន្ទុក ផ្ទះសំបែង ប្រសិនអ្នករស់នៅក្នុងលំនៅដ្ឋានសាធារណៈ។

**ប្រសិនបើអ្នកត្រូវបានគេគំរាមគំហែង ដោយប្រើអំពើហិង្សា ឬការវាយដំដោយអំពើហិង្សា សូមទៅរកប៉ូលីស។**

## ឱវាទផ្លូវច្បាប់ទូទៅ

ប្រសិនបើអ្នកកំពុងគិតអំពីការធ្វើការតវ៉ា អ្នកប្រហែលជាចង់បានឱវាទផ្លូវច្បាប់ ឬទាក់ទងសហជីពរបស់អ្នក។ សេវាកម្មផ្លូវច្បាប់សហគមន៍អាចផ្តល់ឱវាទដោយឥតគិតថ្លៃអំពីការរើសអើង និងការបៀតបៀន។
ព័ត៌មានទំនាក់ទំនងលម្អិតសម្រាប់មជ្ឈមណ្ឌលផ្លូវច្បាប់សហគមន៍ដែលជិតបំផុតរបស់អ្នក ដែលអាចរកបាននៅ www.naclc.org.au/directory។

**ការប្រកាសមិនទទួលខុសត្រូវ៖**
**ព័ត៌មាននៅក្នុងក្រដាសព័ត៌មាននេះមានគោលបំណងតែជាការណែនាំប៉ុណ្ណោះ។**
**វាមិនមែនជាការជំនួសឱ្យឱវាទផ្លូវច្បាប់ទេ។**